# ការបង្ហាញព័ត៌មានទាន់ពេល

ឈ្មោះក្រុមហ៊ុនចុះបញ្ជី :**កំពង់ផែស្វយ័តក្រុងព្រះសីហនុ**

លេខកូដក្រុមហ៊ុនចុះបញ្ជី : KH1000060009

កាលបរិច្ឆេទនិងពេលវេលានៃការបញ្ជូន : ថ្ងៃទី២១ ខែមិថុនា ឆ្នាំ២០២៤, វេលាម៉ោង០៣: ៣០នាទី

## ហេតុការណ៍ពាក់ព័ន្ធនឹងការគ្រប់គ្រង (ទម្រង់ គ.២)

| សេចក្តីប្រកាសព័ត៌មានស្តីពីលទ្ធផលកិច្ចប្រជុំមហាសន្និបាតភាគហ៊ុនិក | |
|---|---|
| ១. កាលបរិច្ឆេទប្រជុំ | ថ្ងៃទី២១ ខែមិថុនា ឆ្នាំ២០២៤ |
| ២. របៀបវារៈ | ម៉ោង ០៧:០០ ការចុះវត្តមាន ភាគហ៊ុនិកចូលរួម<br>ម៉ោង ០៨:០០ គណៈអធិបតី និងភ្ញៀវកិត្តិយសអញ្ជើញដល់<br>ម៉ោង ០៨:១៥ ក. ប្រកាសសមាសភាពគណៈអធិបតី និង ភ្ញៀវកិត្តិយស<br>ខ. គោរពភ្លេងជាតិ<br>ម៉ោង ០៨:៣០ មតិស្វាគមន៍របស់ប្រធានមហាសន្និបាតភាគហ៊ុនិក<br>ម៉ោង ០៨:៤៥ មតិចូលរួមរបស់ភាគហ៊ុនិកជប៉ុន (KAMIGUMI Co., Ltd. និង Kobe -Osaka International Port Corporation)<br>ម៉ោង ០៩:០០ ក. របាយការណ៍ស្តីពីលទ្ធផលការងារអាជីវកម្ម-សេវាកម្មឆ្នាំ ២០២៣, របាយការណ៍ហិរញ្ញវត្ថុប្រចាំឆ្នាំ២០២៣ និងទិសដៅការងារឆ្នាំ ២០២៤<br>ខ. ការណែនាំអំពី នីតិវិធីសម្រាប់ការបោះឆ្នោតបែងចែកភាគលាភជូនភាគហ៊ុនិកសម្រាប់ឆ្នាំ២០២៣ ប្រាក់លាភការក្រុមប្រឹក្សាភិបាល និងមន្ត្រីត្រួតពិនិត្យរដ្ឋអម កសស សម្រាប់ឆ្នាំ២០២៤ និងការបោះឆ្នោតជ្រើសរើសអភិបាលឯករាជ្យ និងអភិបាលមិនប្រតិបត្តិតំណាងភាគហ៊ុនិកឯកជន សម្រាប់ជាសមាជិកក្រុមប្រឹក្សាភិបាល កសស អាណត្តិទី៩<br>ម៉ោង ១០:៣០ សំណួរ-ចម្លើយ<br>ម៉ោង ១០:៤៥ ប្រកាសបើក និងដំណើរការបោះឆ្នោតរយៈពេល ៣០នាទី<br>ម៉ោង ១១:១៥ ប្រកាសលទ្ធផល និង មតិបិទកម្មវិធី |
| ៣. សេចក្តីសង្ខេបនៃលទ្ធផលប្រជុំ | - របាយការណ៍ស្តីពី លទ្ធផលអាជីវកម្ម-សេវាកម្ម ឆ្នាំ២០២៣<br>- របាយការណ៍ ហិរញ្ញវត្ថុ សម្រាប់ដំណាច់ការិយបរិច្ឆេទ ៣១ ធ្នូ ២០២៣ (បានធ្វើសវនកម្ម)<br>- ទិសដៅការងារឆ្នាំ២០២៤<br>- ការអនុម័តការបែងចែកភាគលាភជូនភាគហ៊ុនិក សម្រាប់ឆ្នាំ២០២៣<br>• ភាគហ៊ុនិកប្រភេទ “ខ” មានចំនួន ៥.០០០.០០០.០០០ រៀល<br>• ភាគហ៊ុនិកប្រភេទ “គ” មានចំនួន ១០% នៃតម្លៃ IPO (៥.០៤០រៀល) ស្មើនឹង ១០.៨០៧.២៦៧.៩៦៨ រៀល<br>- ការអនុម័តលើប្រាក់លាភការសម្រាប់ក្រុមប្រឹក្សាភិបាល និងមន្ត្រីត្រួតពិនិត្យរដ្ឋ ឆ្នាំ២០២៤។<br>- ការអនុម័តលើការបោះឆ្នោតជ្រើសតាំងអភិបាលឯករាជ្យ និងអភិបាលមិនប្រតិបត្តិតំណាងភាគហ៊ុនិកឯកជន ជាសមាជិកក្រុមប្រឹក្សាភិបាល អាណត្តិទី៩ របស់ កសស÷ |

| | |
|---|---|
| | • អនុម័តជ្រើសតាំង លោក ហ៊ុន មុន្នីវណ្ណ ជាអភិបាលឯករាជ្យ<br>• អនុម័តជ្រើសតាំង លោក KUME Hidetoshi ជាអភិបាលមិនប្រតិបត្តិតំណាងភាគហ៊ុនិកឯកជន។ |
| ៤. ផ្សេងៗ | |

ហត្ថលេខានិងឈ្មោះបុគ្គលិកទទួលបន្ទុក
ក្នុងការផ្តល់ព័ត៌មាន

សម សុភាព

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**កំពង់ផែស្វយ័តក្រុងព្រះសីហនុ**

លេខ: ០៧៦ សជណ/កសស/រប.ធម

ថ្ងៃសុក្រ ១៥កើត ខែជេស្ឋ ឆ្នាំរោង ឆស័ក ព.ស.២៥៦៨
ខេត្តព្រះសីហនុ, ថ្ងៃទី ២១ ខែ មិថុនា ឆ្នាំ ២០២៤

# សេចក្តីប្រកាសព័ត៌មាន

## ស្តីពី

## លទ្ធផលមហាសន្និបាតភាគហ៊ុនិក លើកទី៧ របស់ កំពង់ផែស្វយ័តក្រុងព្រះសីហនុ (កសស)

កំពង់ផែស្វយ័តក្រុងព្រះសីហនុ (**កសស**) សូមជម្រាបជូនវិនិយោគិន និងសាធារណជនមេត្តាជ្រាបថា ៖ នាថ្ងៃទី២១ ខែមិថុនា ឆ្នាំ២០២៤ វេលាម៉ោង ០៨:០០ ព្រឹក **កសស** បានរៀបចំមហាសន្និបាតភាគហ៊ុនិកលើកទី៧ ក្រោមអធិបតីភាព **ឯកឧត្តម លូ គឹមឈន់** ប្រធានក្រុមប្រឹក្សាភិបាល និងជាប្រធានមហាសន្និបាត ។ អង្គមហាសន្និបាតភាគហ៊ុនិកលើកទី៧ បានរៀបចំឡើងនៅ សណ្ឋាគារ ផ្ទេរ សុខា, ក្រុង- ខេត្តព្រះសីហនុ ដែលមានកូរ៉ុម ចំនួន **៩៤.២៤ %** និងភាគហ៊ុនិកចំនួន **៨០** រូប ស្មើនឹង **៨០,៨៣២,៦៨៤** ភាគហ៊ុន ដោយទទួលបានលទ្ធផលដូចខាងក្រោម ៖

- របាយការណ៍ស្តីពី លទ្ធផលអាជីវកម្ម-សេវាកម្ម ឆ្នាំ២០២៣
- របាយការណ៍ ហិរញ្ញវត្ថុ សម្រាប់ដំណាច់ការិយបរិច្ឆេទ ៣១ ធ្នូ ២០២៣ (បានធ្វើសវនកម្ម)
- ទិសដៅការងារឆ្នាំ២០២៤
- ការអនុម័តការបែងចែកភាគលាភជូនភាគហ៊ុនិក សម្រាប់ឆ្នាំ២០២៣
  - ភាគហ៊ុនិកប្រភេទ "ខ" មានចំនួន ៥,០០០,០០០,០០០ រៀល
  - ភាគហ៊ុនិកប្រភេទ "គ" មានចំនួន **១០%** នៃតម្លៃ IPO (៥.០៤០រៀល) ស្មើនឹង **១០,៨០៧,២៦៧,៩៦៨** រៀល
- ការអនុម័តលើ ប្រាក់លាភការសម្រាប់ក្រុមប្រឹក្សាភិបាល និងមន្រ្តីត្រួតពិនិត្យរដ្ឋ ឆ្នាំ២០២៤
- ការអនុម័តលើ ការបោះឆ្នោតជ្រើសតាំងអភិបាលឯករាជ្យ និងអភិបាលមិនប្រតិបត្តិតំណាងភាគហ៊ុនិកឯកជន ជាសមាជិកក្រុមប្រឹក្សាភិបាល អាណត្តិទី៩ របស់កំពង់ផែស្វយ័តក្រុងព្រះសីហនុ ៖
  - អនុម័តជ្រើសតាំង លោក **ហ៊ុន មុន្នីវណ្ណ** ជាអភិបាលឯករាជ្យ
  - អនុម័តជ្រើសតាំង លោក KUME Hidetoshi ជាអភិបាលមិនប្រតិបត្តិតំណាងភាគហ៊ុនិកឯកជន។

អង្គមហាសន្និបាតភាគហ៊ុនិកលើកទី៧ បានបិទបញ្ចប់នៅវេលាម៉ោង ១២:០០ នាថ្ងៃខែឆ្នាំដដែល ក្រោមបរិយាកាសរីករាយ ស្និទ្ធស្នាល និងការទទួលខុសត្រូវខ្ពស់ ។

អាស្រ័យដូចបានជម្រាបជូនខាងលើ សូមវិនិយោគិន និងសាធារណជនទទួលជ្រាបជាព័ត៌មាន ។

**កំពង់ផែស្វយ័តក្រុងព្រះសីហនុ**

ថ្នល់វិថី សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន សង្កាត់លេខ៣ ក្រុងព្រះសីហនុ ខេត្តព្រះសីហនុ
Tarak Vithei Samdech Akka Moha Sena Padei Techo HUN SEN
Sangkat N° 3, Preah Sihanouk City, Preah Sihanouk Province
Office : 034 933 416; 034 933 511 Pilot : 034 933 507; Fax: 034 933 693
E-mail: pasinfo@pas.gov.kh; spsez@pas.gov.kh
Website: www.pas.gov.kh